# បុណ្យសាងវាលុកចេតិយ
# ពូនភ្នំខ្សាច់

LIBRARY
BUDDHIST INST

២១៤.
៧១

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

# បុណ្យសាងវាលុកចេតិយ
# ពូនភ្នំខ្សាច់


អ្នកនិពន្ធ

## ឃឹម សុវីរ


ឆ្នាំច ឆស័ក


ព.ស. ២៥៣៨ ម.ស. ១៩១៦

គ.ស. ១៩៩៤ ច.ស. ១៣៥៦



រក្សាសិទ្ធិ

LIBRARY BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

នៅច្រើនកន្លែងដែរ ដែលមានគេធ្វើបុណ្យធំ-តូច គេរៀបចំធ្វើ វាលុកចេតិយ (ពូនភ្នំខ្សាច់ ) ។ តែខ្លះធ្វើបែបនេះហើយ ខ្លះធ្វើបែបនោះវិញ មិនដូចគ្នាទេ ពីព្រោះគេមិនដែលបានឃើញឯកសារវាលុកចេតិយ ( ពូនភ្នំខ្សាច់ ) នៅឯណាផង ។

ទើបខ្ញុំបានសំរេចចិត្តដកស្រង់ដោយសង្ខេបចេញពី :

- អានិសង្សវាលុកចេតិយ រឺអានិសង្សពូនភ្នំខ្សាច់
- មហាអនន្តគុណ ខ្សែ ១
- ទ្វាទសមាស
- តាមការសាកសួរនិងតាមការឃើញផ្ទាល់ភ្នែក

មកប្រមែប្រមូលផ្សំផ្សំគំនិតចងក្រង ធ្វើកូនសៀវភៅនេះ ហើយអោយឈ្មោះថា "**បុណ្យកសាងវាលុកចេតិយ**" (ពូនភ្នំខ្សាច់ ) មកបង្ហាញជួយ ១ ជំនាន់ក្រោយអោយបានយល់ដឹងពីវប្បធម៌ អរិយធម៌ខ្មែរ ដែលទាក់ទងនឹងព្រះពុទ្ធសាសនានេះផង ។

សូមអរគុណ

**លី សុចិវ**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

វក្សាសិទ្ធិ

www.budinst.gov.kh www.elibraryofcambodia.org

# ប្រវត្តិសង្ខេប



**លី សុធីរ**

**លី សុធីរ** កើតនៅថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំរោងព.ស.២៤៧២ត្រូវ នឹងថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩២៨ នៅភូមិឬស្សីធ្លង់ ឃុំបឹងព្រះស្រុកបាភ្នំ ខេត្រព្រៃវែង ឪពុកព្រះនាម **លី អែម** ម្តាយព្រះនាម **ទិន ទ៉ាន់**។

ពីអាយុ ១ឆ្នាំ រហូតដល់អាយុ ២០ឆ្នាំ នៅជាមួយឪពុកម្តាយខំរកស៊ីបំរើឪពុកម្តាយ គ្មានបានរៀនសូត្រអ្វីទាំងអស់។ លុះដល់អាយុ២១ឆ្នាំ ឪពុកម្តាយបានអនុញ្ញាតអោយបួសរៀននៅវត្តសិរីមង្គល ហៅព្រៃរវាយ ដែលជាវត្តគេរដំនែលពីឪពុក ស្ថិតនៅក្នុងឃុំទឹកថ្លា ស្រុកបាភ្នំ ខេត្រព្រៃវែង បួសនៅក្នុងសំនាក់ព្រះតេជព្រះគុណ គង់ យិ ជាព្រះឧបជ្ឈាយ៍, ព្រះតេជព្រះគុណ លី អ៊ុម ជាឧបសម្បទាចារ្យ។

www.budinst.gov.kh www.elibraryofcambodia.org

លុះដល់អាយុ ៧២ឆ្នាំ បានចេញទៅរៀនភាសាបាលី នៅវត្តព្រៃទំពូង, វត្តព្រៃកចង្ក្រានឈើ, វត្តសារាវ័ន, វត្តខណ្ឌលោម។ នៅក្នុងគ.ស.១៩៥៦ បានប្រលងជាប់ចូលរៀន នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត។ លុះដល់គ.ស.១៩៦៦បានប្រលងបញ្ចប់បរិញ្ញាប័ត្រទស្សនវិជ្ជាសាសនា នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ។

ពេលលាចាកសិក្ខាបទ នៅឆ្នាំ ១៩៦៦ បានធ្វើជាសាស្ត្រាចារ្យនៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ១ឆ្នាំ បានធ្វើការនៅស្ទួណាព្រុំ ២ឆ្នាំ។

នៅឆ្នាំ ១៩៦៧ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាង ឡាយ ប៊ុនណា នៅភូមិព្រៃកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្ដាល មានកូនស្រី ៥នាក់ និងកូនប្រុស ៣នាក់។ បច្ចុប្បន្នស្លាប់អស់ ២នាក់ នៅរស់កូនស្រី ៣នាក់ និងកូនប្រុស ២នាក់។

នៅឆ្នាំ ១៩៦៩ បានធ្វើជាសាស្ត្រាចារ្យ នៅវិទ្យាល័យសិរីមង្គល (រកាកោង)។ នៅឆ្នាំ ១៩៧២ ធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យខ្មែរអង់គ្លេស (បឹងត្របែក)។ នៅឆ្នាំ ១៩៧៥ ទៅនៅស្រុកកំនើត។ នៅឆ្នាំ ១៩៧៩ ធ្វើគ្រូនៅសាលាបឋមសិក្សាវត្តបឹងព្រះ។ នៅឆ្នាំ ១៩៨០ធ្វើជាអ្នកនិពន្ធសៀវភៅសិក្សានៅក្រសួងអប់រំ។ នៅឆ្នាំ ១៩៩៧ ខែតុលា ចូលនិវត្តន៍។

ភ្នំពេញ, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៥

**លី សុធីរ**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

រក្សាសិទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

# ការកសាងវាលុកចេតិយ

គេយកដីខ្សាច់សុទ្ធ ទៅពូនជា ១ពំនូក រឺជា ៥ពំនូកធ្វើអោយមានរូប ដូចជារាងចេតិយ ហើយគេនាំគ្នាហៅ ថាវាលុកចេតិយ ។ តែអ្នកខ្លះហៅថា " ភ្នំខ្សាច់ " ពីព្រោះគេនាំយកដីខ្សាច់ ទៅពូនជាពំនូកមានរាងដូចភ្នំ ។

តាមទំនៀមខ្មែរ ការកសាងចេតិយនេះ គេសាងជាតំនាងព្រះចូឡាមណីចេតិយ ដែលពួកទេវតាសាងបញ្ចុះព្រះកេសធាតុ និង ព្រះទាឋធាតុ ( ព្រះចង្កូមកែវ ) នៅឋានត្រៃត្រឹង្សសួគ៌ ។ ការកសាងវាលុកចេតិយ និងការធ្វើបុណ្យឆ្លងវាលុកចេតិយនេះ មានផលានិសង្សច្រើនណាស់ ដូចមានបាលីក្នុងគម្ពីរមហាសំការសូត្រសុត្តជាតក បានបញ្ជាក់ថា

វាលុកចេតិយំ កត្វា យេ នរា អថ នារិយោ
អន្នំ បានំ វត្ថំ បុប្ផំ គន្ធវិលេបនាទីនិ
អាហរិត្វា ចេតិយំ បូជំ កត្វា សទ្ធាយ ច
អានិសង្សំ មហប្ផលំ ទ្វេ កុលេ ឧប្បជ្ជន្តិ
ខត្តិយេ ចាបិ ព្រាហ្មណេ ហីនេ កុលេ ន ជាយន្តិ
វាលុកស្ស ឥទំ ផលំ ។
សំក្រាជមារុយ្ហ គច្ឆតិ នវ សំវច្ឆរេយេវ

www.budinst.gov.kh www.elibraryofcambodia.org

តិរច្ឆានេ សត្តេ មោចេន្តិ ទីឃាយុកា សុខវឌ្ឍាតិ ។

នរនារីដែលបានសាងវាលុកចេតិយ ហើយយកបាយទឹក សំពត់ នូវផ្កា គ្រឿងក្រអូប គ្រឿងលាបជាដើម ទៅបូជាព្រះចេតិយនោះ ដោយសទ្ធា នរជននោះ រមែងបានផលានិសង្សច្រើន រមែងទៅកើតក្នុងត្រកូលពីរ គឺក្នុងត្រកូលក្សត្រ ឬក្នុងត្រកូលព្រាហ្មណ៍ រមែងមិនទៅកើតក្នុងត្រកូលថោកទាបឡើយ នេះជាផលនៃការសាងវាលុកចេតិយ ។

ចំណែកអ្នកបានដោះលែងសត្វទាំងឡាយ ក្នុងឱកាសសង្រ្កាន្តចូលឆ្នាំថ្មីនោះ រមែងមានអាយុយឺនយូរ រមែងបានសេចក្តីសុខច្រើន ។

## របៀបសាងវាលុកចេតិយ

ពីបុរាណកាល បើជិតដល់ថ្ងៃសង្រ្កាន្តឆ្នាំថ្មីចូលមកដល់ហើយ លោកអាចារ្យសំរាប់វត្តនីមួយ ៗ ត្រូវដើរពិនិត្យរកកន្លែងសាងវាលុកចេតិយ តើឆ្នាំនេះត្រូវសាងវាលុកចេតិយ នៅត្រង់កន្លែងណា ( ច្រើនសាងវាលុកចេតិយនៅកន្លែងទំនាប ) ។

កាលបើសំរេចកន្លែងសាងវាលុកចេតិយបានហើយ គេត្រូវរៀបចំរក :


www.budinst.gov.kh www.elibraryofcambodia.org

១.ទៅយកដីខ្សាច់នៅកន្លែងណា ដើម្បីអោយបាន ខ្សាច់ពណ៌សល្អ ។

២.ទៅយកឬស្សីពីកន្លែងណា មកធ្វើរាជវ័តិ ។

៣.ធ្វើរានទេវតា ៩ ធ្វើអំពីឈើ មាន៣ ថ្នាក់ដូច គ្នា។

## របៀបដាក់រានទេវតា

រានទេវតាទាំង ៩ នេះ គេយកដាក់ខាងក្នុងរាជវ័តិ ៨ និងខាងក្រៅរាជវ័តិ ១ គឺដាក់បែបនេះ :

ក.រានព្រះយមរាជ ដាក់នៅខាងកើតទន្ទឹមនឹងរោង ព្រះចន្ទ (ទ្វាទសមាស ភាគ១ ទំព័រ ៤០ បន្ទាត់៩) តែ( ទំព័រ ៦៩ បន្ទាត់១៥.១៦ )បានបញ្ជាក់ច្បាស់ថា រានព្រះយមរាជ ជាពិសេសនោះ គេធ្វើនៅខាងក្រៅរាជវ័តិនៅក្នុងទិសឬតី ដូចនេះ ។ នៅទំព័រ ៧០ មានគំរូបបង្ហាញពីពិធីសាងរាលុក ចេតិយ បានច្បាស់ណាស់ ។

ដូចនេះ រានព្រះយមរាជនិងរានព្រះចន្ទ នៅទន្ទឹមគ្នា មែន តែរានព្រះយមរាជនៅខាងក្រៅរាជវ័តិ ឯរានព្រះចន្ទ នៅខាងក្នុងរាជវ័តិ គឺរានព្រះយមរាជនៅខាងកើត ឯរាន ព្រះចន្ទនៅខាងលិចត្រង់គ្នា ។ តែមិនបានបញ្ជាក់ថា រានព្រះ យមរាជបែរមុខទៅទិសណាទេ ។ តែតាមការធ្លាប់ឃើញ នៅកន្លែង រានព្រះយមរាជបែរមុខទៅទិសឬតី ។

www.budinst.gov.kh  www.elibraryofcambodia.org

ខ.ភានទេវតាទាំង៨ ត្រូវដាក់បែរមុខទៅទិសណា ? ត្រូវដាក់បែបណា ?

ក្នុងសៀវភៅទ្វាទសមាស ភាគ១ ទំព័រ៤០ បន្ទាត់៧-៨ បានបញ្ជាក់ថា "ទៅដាក់ភាយជុំវិញព្រះវិហារ តាមទិសទាំង ៨ បំបែរមុខទៅតាមទិសនោះៗ..." ។ បើតាមន័យនេះ ភាន នៅទិសខាងត្បូង ភាននោះត្រូវបែរមុខទៅទិសខាងត្បូង...។ តែត្រង់ទំព័រ៤២ បន្ទាត់៨-៩ បានបញ្ជាក់ថា " ចាងហ្វាងក្រុម រាជបណ្ឌិត ក៏ផ្ដើមនាំអ្នកទាំងនោះសាងភាលុកចេតិយ ដោយ ដីខ្សាច់ធម្មតា នៅត្រង់មុខភានទេវតាទាំង ៨ ទិស បើតាម ន័យនេះ ភានទេវតាទាំង៨ ត្រូវបែរមុខចូលក្នុងវិញ ។

តាមការសង្កេតផ្ទាល់ខ្លួន និងតាមសួរចាស់ៗ បានបញ្ជាក់អោយឃើញថា នៅគ្រប់ការរៀបពិធីផ្សេងៗ នៅក្នុងប្រទេសកម្ពុជា គេឃើញសង់ភានទេវតាទាំង៨ទិស បែរមុខមករកពិធីទាំងអស់ មិនដែលឃើញមានសង់ភានទេវតា បែរមុខចេញឡើយ ។

នៅកន្លែងខ្លះ គេឃើញមានយកភានព្រះយមរាជមកដាក់ពីទិសខាងកើតប៉ែកខាងជើង នៅទន្ទឹមនឹងភានព្រះចន្ទប៉ែកខាងត្បូង បែរមុខចូលក្នុងដែរ ។


www.budinst.gov.kh www.elibraryofcambodia.org

គេសាងរានទេវតា៨ ដើម្បីឧទ្ទិសថ្វាយទេវតាប្រចាំទិសទាំង៨ ដូចមានឈ្មោះខាងក្រោមនេះ :

១. នៅទិសបូព៌ ថ្វាយទេវតាឈ្មោះ ព្រះចន្ទ

២. នៅទិសអាគ្នេយ៍ ថ្វាយទេវតាឈ្មោះ ព្រះអង្គារ

៣. នៅទិសទក្សិណ ថ្វាយទេវតាឈ្មោះ ព្រះពុធ

៤. នៅទិសនីរតី ថ្វាយទេវតាឈ្មោះ ព្រះសៅរ៍

៥. នៅទិសបស្ចិម ថ្វាយទេវតាឈ្មោះ ព្រះព្រហស្បតិ៍

៦. នៅទិសពាយព្យ ថ្វាយទេវតាឈ្មោះ ព្រះរាហូ

៧. នៅទិសឧត្តរ ថ្វាយទេវតាឈ្មោះ ព្រះសុក្រ

៨. នៅទិសឦសាន ថ្វាយទេវតាឈ្មោះ ព្រះអាទិត្យ ។

## សាងវាលុកចេតិយ

របៀបសាងវាលុកចេតិយ ពីបុរាណបែបនេះ

**១. សាងរាជវ័តិ**

របៀបសាងរាជវ័តិ គេច្រើនធ្វើបែបនេះ

ក. គេបិទបន្ទោះឬស្សី សំរាប់ទាស់ខ្វែងធ្វើជាក្រឡា មានកំពស់ប្រវែងប្រហែលជា ១ម៉ែត្រ រឺជាង ១ម៉ែត្រ តាមការស្រលាញ់។ គេយកបន្ទោះឬស្សីនោះ មកទាស់ខ្វែងលើក១សង្កត់ ១ រាងទ្រេតរកគ្នា និងមានប្រវែងបណ្តោយតាមការស្រលាញ់ រឺតាមប្រវែងដីដែលគេកំនត់យក ។ គេទាស់ខ្វែង


www.budinst.gov.kh www.elibraryofcambodia.org

បែបនេះ :



កន្លែងខ្លះ គេដាក់បន្ទោះ តាមបណ្ដោយ នៃចន្លោះនិមួយៗ មានលក្ខណៈ បែបនេះ



ខ-គេយកបន្ទះឫស្សីរាងធំជាងបន្តិច ( រនាប ) មកធ្វើជាក្រប។គេយកបន្ទោះផ្ដៅ រឺ អំពាក់ មកចងភ្ជាប់អោយស្អាត និងកាត់តំរឹមអោយត្រូវតាមខ្នាតដែលខ្លួនចង់បាន ។

គ-គេជីករណ្ដៅដាំបង្គោល គ្រប់កន្លែងចំនួន១២។គេយកផ្ទាំងឫស្សីទៅចងភ្ជាប់នឹងបង្គោលនោះៗ អោយជាប់ដែលហៅថាធ្វើភជរ័តិ ។

***២-គេជីកដាក់ការខឿនតា***



www.budinst.gov.kh www.elibraryofcambodia.org

កាលបើគេធ្វើរាជវ័តិបានហើយ គេត្រូវជីកជីដាំសសររានទេវតាទាំង ៩នោះ ។ តើគេត្រូវធ្វើបែបណា? គេត្រូវជីកជីដាំសសររានទេវតាជារាង ៤ ជ្រុងស្មើបែបនេះ :

ក_នេះជាកន្លែងដាំសសរចងបន្ទោះឬស្សីរាជវ័តិ



ខ_នេះជាកន្លែងជីកជីដាំរានទេវតាទាំង ៩



គំនូសសំគាល់ :

-ភានព្រះយមរាជ បែរមុខទៅទិសបូព៌ា

- ភានទាំង ៨ ត្រូវបែរមុខចូលក្នុងទាំងអស់ ។

គ-កន្លែងខ្លះ គេធ្វើរាជវតិ និងដាក់ភានទេវតា បែបនេះវិញ តែមិនឃើញមានក្បួននិយាយនៅកន្លែងណាទេ គឺតាមការឃើញផ្ទាល់ភ្នែកតែម្តង ។




គំនូសសំគាល់ :

- ទិសខាងកើតមានទ្វារ២ គឺដូចព្រះបរមរាជវាំងយើង នៅក្នុងក្រុងភ្នំពេញ

- ភានព្រះយមរាជ និងភានព្រះចន្ទ នៅទន្ទឹមគ្នាដែរ តែភានព្រះយមរាជ នៅខាងជើង ភានព្រះចន្ទនៅខាងត្បូង ។

-ដាក់មុខភានទាំង ៩ ចូលក្នុង


www.budinst.gov.kh www.elibraryofcambodia.org

- កន្លែងខ្លះទៀត ដាក់ភានទេវតា ខាងក្រៅរាជវ័តិក៏មាន ។ តែតាមយោបល់ផ្ទាល់ខ្លួនខ្ញុំថា ដាក់ភានទេវតាខាងក្រៅរាជវ័តិ មិនត្រឹមត្រូវទេ ។

៣ - ***គេពូនភ្នំខ្សាច់***

ការពូនភ្នំខ្សាច់នេះ នៅកន្លែងខ្លះ គេពូកតែ១ពំនូកធំសំរាប់ជានិមិត្តរូបព្រះចូឡាមណីចេតិយ នៅលើភ្នំព្រះសុមេរុតែម្តង ។ តែកន្លែងខ្លះ គេចាក់ពូនជា៥ ពំនូក គឺពំនូកកណ្តាលធំ តំនាងព្រះចូឡាមណីចេតិយ ពំនូក ៤ តូច នៅជុំវិញពំនូកធំ តំនាងទ្វីបទាំង ៤ ។

គេត្រូវពូក ជាពំនូកបែបនេះ





www.budinst.gov.kh www.elibraryofcambodia.org

## ការពូនភ្នំខ្សាច់ជា ៥ ពំនូកវែបបនេះគឺ

១. ពំនូកធំនៅចំកណ្ដាល ជាតំនាងព្រះចូឡាមណី ចេតិយ ដែលពួកទេវតាសាងបញ្ចុះព្រះកេសធាតុនិងទាឋ ធាតុរបស់ព្រះសម្មាសម្ពុទ្ធ នៅលើឋានត្រៃត្រឹង្ស ។

២. ពំនូកតូចៗ ចំនួន៤ នៅជុំវិញពំនូកធំនោះ ជាតំនាង ទ្វីបទាំង ៤ គឺ:

ក. បុព្វវិទេហទ្វីប ( បូពិវិទេហទ្វីប ) ឈ្មោះទ្វីបធំ ១ រាប់បញ្ចូលក្នុងមហាទ្វីបទាំង ៤ មានព្រះបាទ ធតរដ្ឋ ជាអ្នករក្សាទ្វីបខាងកើតនេះ ។

ខ . ជម្ពូទ្វីប ឈ្មោះទ្វីបធំ ១ ដែលលោកកំនត់ហៅដោយមានដើមព្រីងធំសំបើម ដុះប្រចាំទ្វីបជាគោលចារឹកនៅខាងត្បូងភ្នំព្រះសុមេរុ ។ ទ្វីបនេះ មានព្រះបាទ វិរុឡ្ហក ជាអ្នករក្សាទ្វីប ខាងត្បូងនេះ ។

គ. អបរគោយានទ្វីប ជាឈ្មោះទ្វីបធំ១ នៅទិសខាងលិចភ្នំព្រះសុមេរុ ។ ទ្វីបនេះ មានព្រះបាទ វិរូបក្ខ ជាអ្នកនៅថែរក្សាទ្វីបខាងលិចនេះ ។

ឃ. ឧត្តរកុរុទ្វីប ជាឈ្មោះទ្វីបធំ១ នៅទិសខាងជើងភ្នំព្រះសុមេរុ ( សិនេរុ ) ។ ទ្វីបនេះ មានព្រះបាទ កុវេរៈ ( វេស្សវ័ណ ) ជាអ្នកចាំថែរក្សាទ្វីបនេះ ។


www.budinst.gov.kh www.elibraryofcambodia.org

សូមបញ្ជាក់ថា ភ្នំសុមេរុ (សិនេរុ) នេះ ជាភ្នំខ្ពស់ជាង ភ្នំទាំងអស់ ហើយជាទីតាំងនៃត្រៃត្រឹង្សសួគ៌ ដែលជាស្ថាន របស់ព្រះឥន្ទ ។

នៅលើស្ថានត្រៃត្រឹង្សសួគ៌នេះ មានព្រះចូឡាមណី ចេតិយ ដែលពពួកទេវតាសាងបញ្ចុះព្រះកេសធាតុ និង ព្រះ ទាឋធាតុ របស់សម្មាសម្ពុទ្ធតែ ១ព្រះអង្គគត់ ។ ចុះហេតុអ្វី ក៏អ្នកសាងវាលុកចេតិយមាន ៥ ហើយថាសាងតំនាងព្រះ ចូឡាមណីចេតិយ ខ្ញុំបានឆ្លើយបញ្ជាក់ខាងលើហើយ ។

## ក្រយាចំលង

អរិយធម៌បែបនេះ ខ្ញុំបានឃើញគេមានធ្វើ " ក្រយា ចំលង" ក្នុងពេលឆ្លងបុណ្យ ដូចជាបុណ្យចូលឆ្នាំ បុណ្យ ភ្ជុំបិណ្ឌ ជាដើម ក៏មានលក្ខណៈប្រហាក់ប្រហែលនិងការ កសាងវាលុកចេតិយនេះដែរ ។

## របៀបធ្វើក្រយាចំលង

របៀបធ្វើក្រយាចំលង ( ស្រុកខ្លះហៅថាប្រដាប់ចំ - លង ) នេះ គឺគេយកពែង៥ ពែង១ធំ ឯពែង៤ទៀតតូចជាង ពែងធំបន្តិច ។ គេយកពែងទាំង ៥នេះ ទៅដាក់លើកួនថាស តូចល្មម ។ គេរៀបដាក់ពែងធំ នៅចំកណ្តាល ឯពែងតូច៤

www.budinst.gov.kh www.elibraryofcambodia.org

ទៀតនោះ គេរៀបដាក់នៅជុំវិញពែងធំ ។ នៅក្នុងពែងទាំង៥ នោះ គេដាក់ទឹកក្រអូប ដូចជា ទឹកអប់, ម្សៅក្រអូបយកមកលាយជាមួយនឹងទឹក ។ ទឹកក្នុងពែងនោះ គេហៅថា ទក្ខិណោទក ហៅក្លាយថា ទក្សោទក រឺទឹកស្មោទក ។ នៅជុំវិញពែង រឺចន្លោះពែងទាំង៥នោះ គេដាក់ទៀន ធូប, ផ្លែឈើ ៤ នំចំណីផ្សេងៗ និង បច្ច័យ ( ប្រាក់ ) ។ ពីបុរាណ បច្ច័យដែលបានពីការធ្វើក្រយាចំលងនេះ ទុកអោយលោកអាចារ្យអ្នកមានការនឿយហត់ ។ តែកន្លែងខ្លះ ឃើញគេយកប្រាក់ នេះទៅប្រគេនលោកអោយយកទៅដាក់សំរាប់វត្តវិញ។ បើតាមយោបល់ខ្ញុំ បុរាណគេធ្វើត្រូវជាង ពីព្រោះលោកអាចារ្យច្រើនមានការហត់នឿយខ្លាំង គួរយកប្រាក់នេះបូជាគាត់វិញ។

ពេលព្រឹកបង្អើយ គេត្រូវនិមន្តព្រះសង្ឃសូត្រធម៌ ពហូទេវា....., សកត្វា.....ដារ បង្សុកូលឆ្លងបុណ្យ ។ ពេលព្រះសង្ឃសូត្រធម៌ចប់ អ្នកម្ចាស់ដើមបុណ្យ ដៃឆ្វេងទ្រថាសក្រយាចំលង , ដៃស្តាំកាន់ស្ទន់ដើរទា ( ដើរលុតជង្គង់ ) ចូលទៅរកព្រះសង្ឃដើមអាសន៏មុន។ ពេលចូលទៅដល់ព្រះសង្ឃលាបាតដៃស្តាំហុចមក អ្នកម្ចាស់ដើមបុណ្យយកស្ទន់ត្រវិក្នុងពែងទាំង៥ គឺពែងកណ្តាលមុន បន្ទាប់ ពែងខាងកើត ត្បូង


www.budinst.gov.kh www.elibraryofcambodia.org

លិច ជើង យកទៅរលាស់ដាក់បាត ព្រះហស្តព្រះសង្ឃដើម អាសន៍ និង ព្រះសង្ឃជាបន្ត បន្ទាប់រហូតដល់គ្រប់ព្រះអង្គ ។ ការធ្វើបែបនេះរហូតដល់ អស់អ្នកម្ចាស់ដើមបុណ្យក៏បាន តែម្នាក់ជាតំណាងក៏បាន ។

ប្រសិនបើមានអ្នកឆ្ងល់សួរថា លោកអាចារ្យ ពែង ៥ យកមកដាក់ទឹកក្រអូប តំកល់លើកូនថាសតូចល្មមនេះ ពែងទាំង៥នេះជាតំណាងអ្វី ? លោកអាចារ្យអ្នកធ្វើក្រយាចំលងច្រើន មិនឆ្លើយថាពែងធំនៅចំកណ្ដាល ជាតំណាងភ្នំព្រះសុមេរុ ឯពែងតូចនៅសងខាង ជាតំណាងមហាទ្វីបទាំង ៤ ទេ ។ គាត់ច្រើនតែឆ្លើយថាពែងធំនៅចំកណ្ដាល ជាតំណាងស្ថានព្រះនិព្វាន ឯពែងតូច ៤នោះ ជាតំណាងអន្លង់ ៤ គឺ កាមោឃៈ ភវោឃៈ អវិជ្ជោឃៈ ទិដ្ឋោឃៈ ។

និយាយមកដល់ត្រឹមនេះ ខ្ញុំបាននឹកឃើញកាលខ្ញុំនៅពីក្មេងៗ ជីតា មាតា បិតាខ្ញុំ មុននឹងចូលទៅសំរាន្ដ គាត់តែងតែតំនាលរឿងព្រេងខ្លីៗប្រាប់កូន ប្រាប់ចៅ បែបរឿងកំសាន្តរឺ រឿងកំប្លែង ។ ....។

គាត់បានតំនាលរឿងភ្នំព្រះសុមេរុថា ភ្នំព្រះសុមេរុនៅឆ្ងាយណាស់ មិនមានអ្នកណាម្នាក់ចូលទៅដល់បានទេ ពី-


www.budinst.gov.kh www.elibraryofcambodia.org

ព្រោះ នៅជុំវិញភ្នំព្រះសុមេរុនោះ មានទឹកឥតសរសៃ សូម្បី សំរាមស្រាល អណ្តែតទៅដល់ទីនោះ ក៏លិចបាត់ទាំងអស់ដែរ ។

អ្នកទៅដល់ភ្នំព្រះសុមេរុ មានតែពពួកទេវតាដែលចេះហោះតាមអាកាសទេ ទើបចូលទៅដល់ភ្នំព្រះសុមេរុបាន ។

ប្រហែលជាចាស់បុរាណ គាត់បាននិយាយថា ភ្នំព្រះសុមេរុមានទឹកឥតសរសៃព័ទ្ធជុំវិញ ។ ភ្នំព្រះសុមេរុ ប្រហែលជាគាត់សំដៅយកតួព្រះនិព្វាន និងមានទឹកឥតសរសៃនៅជុំវិញ សំដៅយកអន្លង់កិលេសទាំង ៤ សំរាប់រាំងស្ទះមិនអោយឆ្លងរួចដល់ភ្នំព្រះសុមេរុ ពោលគឺព្រះនិព្វានបានទេដឹង?

កាលមើលគេសាងវាលុកចេតិយ និង រៀបចំបានល្អហើយ គេត្រូវរៀបចំធ្វើបុណ្យ :

ក. ពេលល្ងាច : និមន្តព្រះសង្ឃសូត្រមន្ត និងទេសនាអំពីអានិសង្សពូនភ្នំខ្សាច់ ។

ខ. ពេលព្រឹក : វេរភត្តប្រគេនព្រះសង្ឃ

លុះពីរថ្ងៃបញ្ចប់បុណ្យ គេត្រូវរៀបចំធ្វើក្រយាចំលងហើយនិមន្តព្រះសង្ឃសូត្រធម៌ ពហូ ទេវា ឆ្លងបុណ្យ តាមប្រពៃណីពីបុរាណ ដូចជាឆ្លងបុណ្យដទៃទៀតដែរ ។


www.budinst.gov.kh www.elibraryofcambodia.org

### គេធ្វើបុណ្យកសាងវាលុកចេតិយតើនៅពេលណាខ្លះ ?

ការស្រាវជ្រាវតាមឯកសារនិងការសាកសួរចាស់ ៗ ឃើញថាពីសម័យបុរាណកាល គេធ្វើបុណ្យកសាងវាលុកចេតិយនេះ តែនៅពេលធ្វើបុណ្យចូលឆ្នាំ ៣ ថ្ងៃ ប៉ុននោះ ។

តែជិតដល់ថ្ងៃចូលឆ្នាំហើយ លោកអាចារ្យត្រូវពិនិត្យរកកន្លែងកសាងវាលុកចេតិយ និងរៀបចំកន្លែងកសាងវាលុកចេតិយ ។ ពុទ្ធបរិស័ទជាច្រើន គេប្រមែប្រមូលគ្នាគ្នាទៅជួបជុំនៅទីវត្ត ដែលឋិតនៅជិតផ្ទះខ្លួន ដើម្បីកសាងវាលុកចេតិយ។ មិនត្រឹមតែប៉ុននោះ ខ្លះចូលទៅរួមធ្វើនៅវត្តឆ្ងាយៗក៏មានពីព្រោះគេយល់ បើខ្លួនគេបានទៅចូលរួមធ្វើបុណ្យពូនភ្នំខ្សាច់បាន៧វត្ត ក្នុង១ឆ្នាំ គេនឹងរួចរំដោះចាកទុក្ខទោសទាំងពួង ចាបគ្រោះទាំងឡាយ នឹងវិនាសសាបសូន្យអស់ ។កុសលរាសី នឹងកើតមានដល់ខ្លួនគេជាពិតប្រាកដ ។

តែក្រោយមក គេឃើញមាន គេធ្វើបុណ្យកសាង វាលុកចេតិយ នៅក្នុងពិធីបុណ្យផ្សេងៗជាច្រើន ដូចជាពិធីបុណ្យភ្ជុំបិណ្ឌ, ពុទ្ធាភិសេក, ឆាកមហាបង្សុកូល , ផាវ សូត្រមន្តរំដោះគ្រោះ , សូត្រមន្តយោងព្រះគ្រោះ , សូត្រមន្តប្រទាក់ស្មាព្រហ្ម ...... ។


www.budinst.gov.kh www.elibraryofcambodia.org

គេធ្វើបុណ្យកសាងវាលុកចេតិយនេះ ពីព្រោះគេនាំគ្នាយល់ថា អាចរំដោះកម្មពៀរវេរា ដែលខ្លួនបានធ្វើកន្លងហើយផង អាចកំចាត់បង់បាបគ្រោះទាំងឡាយផង ។

ពិធីបុណ្យតូចៗ គេកសាងវាលុកចេតិយរបៀបផ្សេង មិនដូចជាពិធីធ្វើបុណ្យធំៗទេ គឺគេគ្រាន់តែយកដីខ្សាច់សល្អមកពូកជា ៥ ពំនូក។ ពំនូកកណ្តាលធំ ពំនូក ៤ នៅជុំវិញតូចៗ។

ពំនូកខ្សាច់គរពូនជាភ្នំមួយៗ មានចំនួនគ្រាប់ខ្សាច់ច្រើនណាស់ បើយើងមានកម្មពៀរ ត្រូវរាប់គ្រាប់ខ្សាច់អស់ ។ បើរាប់មិនអស់ទេ ពៀរវេរានឹងរលត់រលាយទៅបាត់ដោយឯង ។ ដូចជាមានរឿងតំនាលថា មាននាយនេសាទ ១នាក់ ( មិនប្រាកដឈ្មោះ ) បានធ្វើតែអំពើបាបកម្មសំលាប់សត្វយកមកបរិភោគ តាំងពី តូចរហូតដល់ចាស់ ។

សម័យថ្ងៃមួយ មានភិក្ខុសង្ឃ ១អង្គ នឹកអាណិតនាយនេសាទខ្លាំងណាស់ ។ ភិក្ខុនោះខំរកមធ្យោបាយអោយនាយនេសាទបានធ្វើបុណ្យខ្លះ ។ ភិក្ខុនោះព្រះអង្គឃ្លុំចីពរ កាន់បាត្រ និមន្តទៅរង់ចាំនាយនេសាទ ។

វេលាព្រឹកថ្ងៃនោះ នាយនេសាទលីលំពែង ១ និងពុនបាយ១កញ្ចប់ ដើរទៅព្រៃស្វែងរកសត្វយកមកចិញ្ចឹមជីវិត ។


www.budinst.gov.kh www.elibraryofcambodia.org

កាលបើឃើញនាយនេសាទភ្ញាម ភិក្ខុនោះនិមន្តចូលទៅបិណ្ឌបាត្របាយកញ្ចប់ ។ នាយនេសាទប្រកែកដាច់ខាតថា មិនព្រមប្រគេនទេ តែភិក្ខុនោះចេះតែទទូចសុំជាច្រើនដង អត់ទ្រាំមិនបាន ក៏រំលែកបាយ ១ ពំនូតប្រគេនភិក្ខុនោះ ។

ថ្ងៃក្រោយមក នាយនេសាទរំលាងខន្ធទៅ យមបាលចាប់យកទៅសួរចំលើយថា កាលនៅជាមនុស្សលោក បានធ្វើបុណ្យអ្វីខ្លះ ? នាយនេសាទឆ្លើយតបវិញថា ខ្ញុំមិនបានធ្វើបុណ្យអ្វីទេ ធ្វើតែបាបកម្មតាំងពីតូច ។

យមបាល ក៏ចាប់ទៅបោះនៅក្នុងរណ្តៅភ្លើងនរក តែមិនឆេះ ចេះតែខ្ទាតចេញមកក្រៅ ។ យមបាលនឹកឆ្ងល់ក៏សួរបញ្ជាក់ថែមទៀតថា អ្នកបានធ្វើបុណ្យអ្វី ? នាយនេសាទក្រឡេកឃើញអណ្តាតភ្លើងនរក មានពណ៌ដូចជាចីពរលោកសង្ឃ ក៏នឹកឃើញទាន់ដែលខ្លួនបានធ្វើ ។ នាយនេសាទបានឆ្លើយតបថា កាលខ្ញុំនៅជាមនុស្ស ខ្ញុំបានប្រគេនបាយ១ពំនូតដល់ភិក្ខុ ១អង្គដែរ ។ពួកយមបាលប្រាប់ថា បើដូចនោះ អ្នកឯងបានទៅកើតឋានសួគ៌ ១ អាទិត្យ ។

លុះដល់ថ្ងៃទី ៨ យើងនឹងយកខ្លួនអ្នកឯង អោយមកទទួលទោសនៅឋាននរកវិញ ។ ក្នុង១រំពេចនោះ វិញ្ញាណរបស់អ្នកនេសាទ បានទៅកើតឋានសួគ៌ ឈ្មោះថា អន្ទិ


www.budinst.gov.kh www.elibraryofcambodia.org

លោកង្សិនីទេវបុត្រ ។ ទេវបុត្រនេះ មានវិមាន ១២ យោជន៍ បរិបូរទៅដោយសម្បត្តិ និង ទេពកញ្ញាបំរើត្រៀបត្រា មាននាងសុវណ្ណឱរៃជាទេពី ។ អន្ទំលោកង្សិនីទេវបុត្រ សោយសម្បត្តិបាន ៦ថ្ងៃ នឹកឃើញដល់បណ្តាំយមបាល ក៏កើតសេចក្តីទុក្ខទោសពន់ប្រមាណ ហើយចូលទៅដេក ។ នាងសុវណ្ណឱរៃ ឃើញអាការៈដូចនោះ ក៏ចូលទៅសាកសួរ ។ ទេវបុត្រអន្ទំលោកង្សិនី បានរ៉ាយរ៉ាប់ប្រាប់រឿងតាំងពីដើមរហូតដល់ចប់ ។

នាងសុវណ្ណឱរៃ លួងលោមថា បើដូចនោះ សូមព្រះអង្គកុំជាទុក្ខទោមនស្សឡើយ ពីព្រោះព្រះពុទ្ធសំដែងថា "ទោះអ្នកណាធ្វើបាបអម្បាលម៉ានក្តី បើចង់អោយរួចអំពីកម្មពៀរ ដែលបានធ្វើហើយ ត្រូវកសាងវាលុកចេតិយ ធ្វើបុណ្យឆ្លង នឹងរួចផុតពីកម្មពៀរនោះឯង " ។ ហេតុនេះ សូមព្រះអង្គធ្វើតាមព្រះបន្ទូលនេះចុះ ទៀងជារំដោះរួចផុតពីកម្មពៀរជាពិតប្រាកដ ។

អន្ទំលោកង្សិនីទេវបុត្រ បានលឺដូចនោះ ក៏មានចិត្តសោមនស្សរីករាយ ទើបចាត់ការកសាងវាលុកចេតិយ និងធ្វើបុណ្យឆ្លងហើយស្រេចក្នុងរវាងថ្ងៃទី ៧ នោះឯង ។


www.budinst.gov.kh www.elibraryofcambodia.org

លុះដល់ថ្ងៃទី ៨ វេលាព្រឹកព្រហាម ពួកយមបាលក៏ទៅដល់ ស្រែកហៅរកខ្លួនអន្ទំលោកឃ្សិនីទេវបុត្រ អោយចេញមក ។ គ្រានោះ អន្ទំលោកឃ្សិនីទេវបុត្រ គេចមុខចេញ នាងសុវណ្ណឱរៃ ចេញមកនិយាយជាសំនួរតបមកយមបាលថា យើងមិនព្រមបើកអោយស្វាមីយើងចេញទេ ពីព្រោះស្វាមីយើងបានកសាងវាលុកចេតិយ និងធ្វើបុណ្យឆ្លងរួចហើយ បាបកម្មទាំងពួង ក៏ជ្រះអស់ពីខ្លួនហើយ ។ តែយមបាលនៅតែត្រូវការ យកខ្លួនប្ដីខ្ញុំទៅធ្វើទោសត្រូវរាប់គ្រាប់ខ្សាច់ ១ពែងនេះអោយអស់ បើរាប់អស់គ្រាប់ខ្សាច់ដែលនៅក្នុងពែងនេះ ទើបយកទៅបាន ។

យមបាលតបថា មិនសល់ក្រអ្វីទេ ការរាប់គ្រាប់ខ្សាច់ប៉ុននេះ ទើបយមបាល នាំគ្នារាប់គ្រាប់ខ្សាច់ក្នុងពែងនេះ តាំងពីក្នុងពែងដាក់មកខាងក្រៅ ទៅដាក់គរជាគំនរយ៉ាងធំកំពស់ស្មើនឹងដើមត្នោត ។ តែគ្រាប់ខ្សាច់នៅក្នុងពែងគង់នៅដដែល គ្មានស្រកស្រុតអ្វីសោះ ។ ពួកយមបាលទាល់ចំនេះនឹងរាប់ ហើយក៏នាំគ្នាត្រលប់ទៅយមលោកវិញ ។

ចំនែកអន្ទំលោកឃ្សិនីទេវបុត្រ បាននៅសោយសម្បត្តិក្នុងទេវលោក អស់កាលជាអង្វែងតមកទៀត មិនបានទៅ


www.budinst.gov.kh www.elibraryofcambodia.org

សោយទុក្ខក្នុងនរក ដូចយមបាលកំនត់ទុកនោះទេ ។ ទាំងនេះ ក៏ដោយអំនាចផលានិសង្ស ដែលបានសាងវាលុកចេតិយ និង ធ្វើបុណ្យឆ្លង ដូចពោលមកហើយ ។

*ធ្វើចប់នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៥*

**លី សុធីរ**

សាស្ត្រាចារ្យមធ្យមសិក្សា

*រក្សាសិទ្ធិ*

*អ្នកវាយកុំព្យូទ័រ នាង សុខ ចិន្តា*


www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org